## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ១៤ កញ្ញា ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 14-Sep-2012, 11:39
CMS/CFO: Uch Arun

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# ចម្លើយតបរបស់លោក អៀង សារី អនុលោមតាមវិធាន៨៧(៤) ទៅនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា សុំកោះហៅសាក្សី TCW-505, TCW-754, TCW-100, TCE-33, TCW-720, TCW-781 និងសាក្សី TCW-164

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី អៀង សារី**

អាង ឧត្តម

Michael G. KARNAVAS

**ចម្លងជូន:**

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង:**

ចៅក្រម **និល ណុន**

ចៅក្រម **យុរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធូ មន្នី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះ សូមធ្វើការឆ្លើយតបទៅនឹងសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញាសុំកោះហៅសាក្សី TCW-505, TCW-754, TCW-100, TCE-33, TCW-720, TCW-781 និងសាក្សី TCW-164[1]។ ចម្លើយតបនេះត្រូវបានរៀបចំឡើងជាចាំបាច់ ដោយហេតុថា ភាពយឺតយ៉ាវរបស់ការិយាល័យសហព្រះរាជអាជ្ញា ក្នុងការដាក់សំណើសុំរបស់ខ្លួនធ្វើឱ្យមេធាវីការពារក្តីពុំអាចអនុវត្តកាតព្វកិច្ចដោយមានការយកចិត្តទុកដាក់របស់ខ្លួន និងឆ្លើយតបទៅនឹងសំណើនេះក្នុងលក្ខណៈសមស្របមួយនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២[2]។ ការិយាល័យសហព្រះរាជអាជ្ញាបានខកខានពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងការបង្ហាញថា មាន “សំអាងហេតុសមស្រប”[3] សម្រាប់សាក្សីថ្មីៗ ដែលទើបស្នើសុំឱ្យមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ។ នេះគឺជាការប៉ុនប៉ងគេចចេញពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ហើយនឹងធ្វើឱ្យប៉ះពាល់ដល់គោលបំណងនៃការបំបែកសំណុំរឿង ដើម្បីមានការជំនុំជម្រះប្រកបដោយប្រសិទ្ធផល និងខ្លី និងដើម្បីទទួលបានសាលក្រម នៅពេលដែលជនជាប់ចោទទាំងអស់នៅមានជីវិតនៅឡើយ[4]។ ជាងនេះទៀត សាក្សីទាំងនេះនឹងពន្យារពេលកិច្ចដំណើរការនីតិវិធីដោយពុំចាំបាច់ ដែលបណ្តាលឱ្យលោក អៀង សារី នៅជាប់

---

[1] សំណើនេះត្រូវបានដាក់បញ្ចូលនៅក្នុងសេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗ ដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ (ដោយមានឧបសម្ព័ន្ធសម្ងាត់ ក) ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ ឯកសារ E218/2 និងក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២។

[2] សម្រាប់ព័ត៌មានស្តីពីការដាក់ឯកសារដ៏យឺតយ៉ាវនេះ ដែលបានជូនដំណឹងមកក្រុមមេធាវីការពារក្តី តែមួយថ្ងៃគត់ មុនកិច្ចប្រជុំរៀបចំសវនការ *សូមមើល* ញត្តិរបស់ អៀង សារី សុំលុបចោល *សេចក្តីជូនដំណឹងនៃជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗ ដែលត្រូវពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី១៧ ខែសីហា* និងឧបសម្ព័ន្ធរបស់ខ្លួន ឬជាជម្រើសមួយផ្សេងទៀត ស្នើសុំឆ្លើយតបចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១២ ឯកសារ E218/3។

[3] សូមមើល ប្រតិចារឹក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/114.1 ទំព័រ១៨ [ភាសាខ្មែរ ទំព័រ១៤]៖ “អង្គជំនុំជម្រះពិចារណាឃើញថា ការកោះហៅបុគ្គលទាំងអស់នេះនឹងមិននាំឱ្យមានប្រសិទ្ធភាពដំណើរការសវនាការដោយឆាប់រហ័សនោះទេ។ ហើយអង្គជំនុំជម្រះមានភាពស្ទាក់ស្ទើរនៅក្នុងការកោះហៅបុគ្គលទាំងអស់នេះ នៅពេលដែលគ្មានសំអាងហេតុសមស្របនោះ”។

[4] “ការបំបែកកិច្ចដំណើរការនីតិវិធីផ្តល់លទ្ធភាពឱ្យអង្គជំនុំជម្រះអាចចេញសាលក្រមបាន បន្ទាប់ពីការជំនុំជម្រះខ្លីនេះ ការពារបាននូវផលប្រយោជន៍ជាសារវ័ន្តរបស់ជនរងគ្រោះ ក្នុងការទទួលបាននូវយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា ព្រមទាំងការពារបាននូវសិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័សរបស់ជនជាប់ចោទ ទាំងអស់នៅក្នុងសំណុំរឿង០០២ ទៀតផង" ដីកាសម្រេច អនុលោមតាមវិធាន៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E124 កថាខណ្ឌ៨។

ឃុំជិតប្រាំឆ្នាំហើយ បើទោះជាសិទ្ធិរបស់គាត់ស្របតាមច្បាប់រដ្ឋធម្មនុញ្ញតម្រូវថា គាត់ត្រូវសន្មតថាគ្មានទោសក្តី[5]។

## I. ចម្លើយតប

1. ការិយាល័យសហព្រះរាជអាជ្ញាស្នើសុំបន្ថែមសាក្សីមួយចំនួន ដែលយោងទៅតាមសេចក្តីសង្ខេបអំពីសាក្សីរបស់ការិយាល័យនេះ សាក្សីទាំងនេះមានទំនាក់ទំនងយ៉ាងខ្លាំងនឹងចំណុចដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១។ ប្រសិនបើសាក្សីទាំងនេះផ្តល់សក្ខីកម្មនោះ ការិយាល័យសហព្រះរាជអាជ្ញានឹងព្យាយាមសាកសួរពួកគេអំពីចំណុចនានា ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ ដោយអះអាងថា ការសួរសំណួរបែបនេះ ពាក់ព័ន្ធនឹងសាវតារ ឬបរិបទ ឬថាសាក្សីទាំងនេះអាចនឹងពុំមានវត្តមាននៅពេលក្រោយបាន ប្រសិនបើពួកគេមិនត្រូវបានសួរពេលនេះដើម្បីស្វែងយល់ឱ្យអស់អំពីចំណេះដឹងរបស់ពួកគេទេនោះ ឬថា "សក្ខីកម្មបែបនេះ មានសារៈសំខាន់ជាសារវ័ន្តពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម ដែលសហព្រះរាជអាជ្ញាត្រូវបង្ហាញនូវបន្ទុកនេះ"[6]។ ការឱ្យយោបល់ផ្ទុយទីនេះ គឺជាសំដីមិនបានការ។ ការិយាល័យសហព្រះរាជអាជ្ញាស្នើសុំឱ្យ សាក្សីមួយចំនួននៃសាក្សីទាំងនេះជំនួសសាក្សីផ្សេងៗទៀត ដោយហេតុថា បុគ្គលទាំងនេះជាសាក្សីប្រសើរជាង[7]។ ការជំនួសសាក្សីមួយចំនួនដោយមនុស្សផ្សេងទៀត អាចធ្វើទៅបាន លុះត្រាណាតែសក្ខីកម្មរបស់សាក្សីដែលដាក់មកជំនួសនោះ អាច*បន្ថែម* តម្លៃដល់សំណុំរឿង០០២/០១ *ដោយពុំ* ពង្រីកវិសាលភាពរបស់សំណុំរឿងនេះ។ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតបញ្ជីសាក្សីបច្ចុប្បន្នរបស់ខ្លួន តាមការសន្មតបន្ទាប់ពីពិនិត្យសំណុំរឿងទាំងមូលហើយ ជាពិសេសសេចក្តីសង្ខេបអំពីសាក្សី ដែលការិយាល័យសហព្រះរាជអាជ្ញាបានរៀបចំ និងចម្លើយសាក្សីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប្រសិនបើសេចក្តីសង្ខេបច្បាប់ដើមអំពីសាក្សីដែលបានស្នើសុំ ពុំបានបង្ហាញថា សាក្សីទាំងនេះអាចផ្តល់សក្ខីកម្មសំខាន់ៗស្តីពីចំណុចពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ទេនោះ នោះមានន័យថា ការស្នើសុំបន្ថែមសាក្សី

[5] មាត្រា៣៨នៃច្បាប់រដ្ឋធម្មនុញ្ញចែងថា "ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ"។

[6] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/114.1 ទំព័រ២២ [ភាសាខ្មែរ ទំព័រ១៧]។

[7] *ដូចជើងទំព័រខាងលើ* ទំព័រ២០-២១។

ថ្មីៗទាំងនេះ គឺជាការប៉ុនប៉ងពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១។ ទស្សនៈរបស់មេធាវីការពារពាក់ព័ន្ធនឹងសាក្សីនីមួយៗដែលបានស្នើសុំទាំងនេះ មានដូចខាងក្រោម។

**ក. សាក្សី TCW-505**

2. សេចក្តីសង្ខេបពីសាក្សីនេះរបស់ការិយាល័យសហព្រះរាជអាជ្ញាបានដាក់ "មន្ទីរសន្តិសុខ ក្រាំងតាចាន់" "សំអាងហេតុនៃសហឧក្រិដ្ឋកម្មរួម - សហករណ៍ និងការដ្ឋាន *[168 ដល់ 177]*, មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស *[178 ដល់ 204]*។ សហករណ៍ត្រាំកក់ – រចនាសម្ព័ន្ធ និងបុគ្គលិក *[304 ដល់ 309]*, សន្តិសុខ *[315 ដល់ 318]*; ការដ្ឋានស្រែអំបិល – រចនាសម្ព័ន្ធ និងបុគ្គលិក *[371 ដល់ 375]*" និង "អៀង សារី Sary – សហករណ៍ និងការដ្ឋាន – ចំណេះដឹង និងការអនុវត្តគោលនយោបាយនេះ *[1043 ដល់ 1047]*" ថាជាបញ្ហាពាក់ព័ន្ធ។ គ្មានបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងនេះ ជាចំណែកនៃសំណុំរឿង០០២/០១ ឡើយ។ ការពិភាក្សាអំពីប្រធានបទណាមួយក្នុងចំណោមប្រធានបទទាំងនេះក្នុងសំណុំរឿង ០០២/០១ នឹងបំពារបំពានដល់ការចែងកំណត់នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងពិសេសពង្រីកវិសាលភាពនៃការជំនុំជម្រះលើកទីមួយ។ ប្រសិនបើសាក្សីនេះត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម មិនត្រូវអនុញ្ញាតឲ្យគាត់ពិភាក្សាអំពីប្រធានបទទាំងនេះទេ។

3. ក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការនាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ការិយាល័យសហព្រះរាជអាជ្ញាថ្លែងថា សាក្សី TCW-505 អាចផ្តល់ "ព័ត៌មានសំខាន់ៗបំផុតទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ"[8]។ ព័ត៌មាននេះពុំមានក្នុងសេចក្តីសង្ខេបអំពីសាក្សីនេះ[9] របស់ការិយាល័យសហព្រះរាជអាជ្ញាទេ ហើយទំនងពុំចាំបាច់ផង ខណៈដែលសាក្សីផ្សេងៗមួយចំនួនទៀត និងសូម្បីតែលោក នួន ជា ក៏បាននិយាយ និងរំពឹងថានឹងនិយាយអំពីការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញដែរ[10]។ សក្ខីកម្មបន្ថែមទៀតស្តីពីប្រធានបទនេះនឹងគ្រាន់តែជាការលើកឡើងច្រំដែលៗប៉ុណ្ណោះ។ ក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការ ការិយាល័យសហព្រះរាជអាជ្ញាក៏លើកឡើងអំពីសារៈសំខាន់នៃបញ្ជីឯកសារស្រុកត្រាំកក់ និងបង្ហាញថា សាក្សី TCW-505 ជាសាក្សីដ៏ល្អបំផុត ក្នុងការពិភាក្សាអំពីការប្រាស្រ័យទាក់ទង និង

---

[8] *ដូចជើងទំព័រខាងលើ* ទំព័រ១៩។

[9] *សូមមើល* សេចក្តីសង្ខេបអំពីអ្នកជំនាញ, ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ជាមួយនឹងចំណុច ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ – ការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E9/13.1 ទំព័រ៩២។

[10] *សូមមើល* ឧ. សក្ខីកម្មរបស់ នួន ជា, កាំង ហ្គេកអ៊ាវ ហៅ ឌុច, នី កន, សគីម លួត និង ស សៀក។

វចនាសម្ព័ន្ធធ្វើរបាយការណ៍។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ព្រមកោះហៅសាក្សីនេះ ការិយាល័យសហព្រះរាជអាជ្ញាគួរត្រូវបានតម្រូវឱ្យផ្តល់ ក្នុងរយៈពេលដ៏ខ្លីកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង នូវបញ្ជីឯកសារទាំងអស់ ដែលខ្លួនមានចេតនាចង់ប្រើប្រាស់ក្នុងពេលផ្តល់សក្ខីកម្មរបស់សាក្សីនេះ។ អង្គជំនុំជម្រះសាលាដំបូងគួរត្រៀមរយៈពេល ៦ ទៅ ៨ ថ្ងៃ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ។

### ខ. សាក្សី TCW-754 និងសាក្សី TCW-100

4. នៅក្នុងកិច្ចប្រជុំរៀបចំសវនាការនាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ការិយាល័យសហព្រះរាជអាជ្ញាថ្លែងថា ខ្លួនស្នើសុំឱ្យសាក្សីទាំងពីរនេះបកស្រាយអំពីបញ្ហាវចនាសម្ព័ន្ធយោធា និងថា ខ្លួនបានស្នើសុំដកសាក្សីម្នាក់ ឬពីរនាក់ផ្សេងទៀត ពាក់ព័ន្ធនឹងវចនាសម្ព័ន្ធយោធា ដោយហេតុថា ខ្លួនជឿជាក់ថា សាក្សី TCW-754 និងសាក្សី TCW-100 ជាសាក្សីល្អជាង[11]។ គោលជំហររបស់មេធាវីការពារក្តីពីការជំនួសសាក្សីត្រូវបានបង្ហាញជូនខាងលើរួចហើយ។ ការព្រួយបារម្ភជាចម្បងគឺថា សាក្សីថ្មីៗទាំងនេះអាចត្រូវបានសួរដេញដោលអំពីចំណុចនានាក្នុងសេចក្តីសង្ខេបអំពីសាក្សីទាំងនេះ ដូចជា ជម្លោះប្រដាប់អាវុធ មន្ទីរសន្តិសុខអូរកន្សែង ការប្រព្រឹត្តលើជនជាតិវៀតណាម និងមន្ទីរ ស-២១ (លុះត្រាណាតែអង្គជំនុំជម្រះសាលាដំបូងសម្រេចពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ដើម្បីដាក់បញ្ចូលទាំងមន្ទីរ ស-២១ ដូចបានពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២)[12]។ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការនាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ការិយាល័យសហព្រះរាជអាជ្ញាបានអះអាងថា សក្ខីកម្មរបស់សាក្សី TCW-100 "មានសារៈសំខាន់ជាសារវ័ន្តពាក់ព័ន្ធទៅនឹង[សហឧក្រិដ្ឋកម្មរួម("JCE")] ដែលសហព្រះរាជអាជ្ញាព្យាយាមបង្ហាញ"[13]។ ការអះអាងថា សក្ខីកម្មមានលក្ខណៈចាំបាច់ក្នុងការបង្ហាញអំពីសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទប្រកាន់ គ្មានន័យអ្វីទាំងអស់ ព្រោះថាសក្ខីកម្មទាំងអស់ដែលបានស្តាប់ក្នុងដំណាក់កាលជំនុំជម្រះនេះ មានភាពពាក់ព័ន្ធក្នុងកម្រិតណាមួយទៅនឹងការបង្ហាញអំពីការកើតមានសហឧក្រិដ្ឋកម្មរួម ឬការបង្ហាញថាមិនមានសហឧក្រិដ្ឋកម្មរួមដូចការ

---

[11] ប្រតិចារិក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/114.1 ទំព័រ២០-២១។

[12] *សូមមើល* សេចក្តីសង្ខេបអំពីអ្នកជំនាញ, ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ជាមួយនឹងចំណុច ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ – ការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E9/13.1 ទំព័រ៣៦-៣៧ និង៩៧-៩៨។

[13] ប្រតិចារិក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ឯការ E1/114.1 ទំព័រ២២។

ចោទប្រកាន់ឡើយ។ ការប្រើប្រាស់ហេតុផលបែបតក្កដោយបន្ទំរបស់ការិយាល័យសហព្រះរាជអាជ្ញា គឺជាមធ្យោបាយមួយ ដើម្បីបើកផ្លូវដើម្បីស្តាប់ប្រធានបទណាមួយ ដែលការិយាល័យសហព្រះរាជអាជ្ញា ព្យាយាមចម្រាញ់យកសក្ខីកម្ម និងដាក់សម្ពាធដោយមិនត្រឹមត្រូវលើអង្គជំនុំជម្រះ សាលាដំបូង ដើម្បីអនុញ្ញាតឲ្យមានការដេញដោល ស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១។ យុទ្ធវិធីប្រភេទនេះត្រូវបានរៀបចំដើម្បីបំពេញបំណងមតិសាធារណៈ ដើម្បីជាមធ្យោបាយមួយនៃការដាក់សម្ពាធទៅលើអង្គជំនុំជម្រះសាលាដំបូង ដើម្បីអនុញ្ញាតឲ្យមានការជ្រួតជ្រាបអំពីបញ្ហាពុំពាក់ព័ន្ធនឹងសំណុំរឿង០០២/០១។

## គ. សាក្សីអ្នកជំនាញ TCE-33

5. ការិយាល័យសហព្រះរាជអាជ្ញាខកខានពុំបានបង្ហាញ "សំអាងហេតុសមស្រប"[14] ថា សាក្សីអ្នកជំនាញ TCE-33 ចាំបាច់ត្រូវមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ។ តាមពិត សហព្រះរាជអាជ្ញារង លោក Dale Lysak បានឯកភាពថា សាក្សីអ្នកជំនាញ TCE-33 "ជាសាក្សីមួយដែលត្រូវការពេលវេលាច្រើនណាស់ គាត់ជាសាក្សីម្នាក់ដែលមានលក្ខណៈចម្រូងចម្រាស"[15]។ សំអាងហេតុតែមួយគត់ដែលបានផ្តល់ជូននៅក្នុង កិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ គឺថា៖

> ក្នុងចំណោមមនុស្សនៅក្នុងពិភពលោក ប្រសិនណាមានមនុស្សណាម្នាក់ដែលយើងអាចទទួលការពន្យល់អំពីមនោគមវិជ្ជាកុម្មុយនីស្ត ដែលមានអត្ថិភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នោះគាត់ពិតជាមនុស្សតែម្នាក់នោះឯង។ ម្យ៉ាងវិញទៀត គាត់ក៏ជាមនុស្សម្នាក់ដែលបានធ្វើការសម្ភាសសំខាន់ៗជាច្រើនជាមួយនឹងជនជាប់ចោទមួយចំនួនដែរ"[16]។

អង្គជំនុំជម្រះសាលាដំបូងពុំចាំបាច់ឲ្យសាក្សីអ្នកជំនាញ TCE-33 ពន្យល់អំពីមនោគមវិជ្ជាកុម្មុយនីស្តទេ ត្បិតវាពុំមែនជាបញ្ហាមួយដែលមានភាពចម្រូងចម្រាស់ ឬជាបញ្ហាមួយដែលត្រូវការការអធិប្បាយដោយ "អ្នក ជំនាញ" នោះដែរ។ បន្ថែមលើនេះទៀត ការិយាល័យសហព្រះរាជអាជ្ញាខកខានពុំបានផ្តល់

[14] *សូមមើលជើងទំព័រខាងលើ* ទំព័រ១៨ [ភាសាខ្មែរ ទំព័រ១៤]៖ "អង្គជំនុំជម្រះពិចារណាឃើញថា ការកោះហៅបុគ្គលទាំងអស់នេះនឹងមិននាំឲ្យមានប្រសិទ្ធភាពដំណើរការសវនាការដោយឆាប់រហ័សនោះទេ។ ហើយអង្គជំនុំជម្រះមានភាពស្ទាក់ស្ទើរនៅក្នុងការកោះហៅបុគ្គលទាំងអស់នេះ នៅពេលដែលគ្មានសំអាងហេតុសមស្របនោះ"។

[15] *ដូចជើងទំព័រខាងលើ* ទំព័រ២២ [ភាសាខ្មែរ ទំព័រ១៧]។

[16] *ដូចជើងទំព័រខាងលើ* ទំព័រ២២-២៣ [ភាសាខ្មែរ ទំព័រ១៧]។

សំអាងហេតុណាមួយ សមស្រប ឬមិនសមស្រប អំពីមូលហេតុដែលថាមានតែសាក្សីអ្នកជំនាញ TCE-33 នេះទេដែលមាន សមត្ថភាពពិភាក្សាអំពីមនោគមវិជ្ជាកុម្មុយនីស្តនេះនោះ។ លោក នួន ជា ក៏ដូចជាសាក្សីមួយចំនួនផ្សេងទៀត បើទោះជាដោយសង្ខេបក៏ដោយ បានពិភាក្សាអំពីមនោគមវិជ្ជាកុម្មុយនីស្តនេះរួចហើយ[17]។ លោកសាស្ត្រាចារ្យ Chandler ជាប្រវត្តិវិទូ ដែលមានចំណេះដឹង ជាមួយនឹងបទពិសោធន៍ក្នុងប្រទេសកម្ពុជា ចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៦០ មក និងបានណែនាំការសិក្សាថ្នាក់បណ្ឌិតអំពីប្រវត្តិសាស្ត្រកម្ពុជារបស់លោកសាស្ត្រាចារ្យ Kiernan[18] គួរតែត្រូវបានសួរដេញដោលអំពីមនោគមវិជ្ជាកុម្មុយនីស្ត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង ឬការិយាល័យសហព្រះរាជអាជ្ញាយល់ឃើញថាមានសារៈសំខាន់ ក្នុងការគូសបញ្ជាក់អំពីបញ្ហានានានោះ។ ការិយាល័យសហព្រះរាជអាជ្ញាក៏ខកខានពុំបានពន្យល់អំពី មូលហេតុដែលអ្នកជំនាញគ្រោងនឹងឡើងផ្តល់សក្ខីកម្មក្នុងខែតុលា ឆ្នាំ២០១២ ពុំមានលទ្ធភាពបញ្ជាក់ អំពីបញ្ហាទាំងនេះបាន។

6. ការដែលសាក្សីអ្នកជំនាញ TCE-33 ធ្លាប់បានសម្ភាសជាមួយជនជាប់ចោទខ្លះ ពុំមែនជាមូលហេតុគ្រប់គ្រាន់មួយ ក្នុងការកោះហៅរូបគាត់មកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញឡើយ។ អ្នកជំនាញបច្ចុប្បន្ន ដែលគ្រោងនឹងឡើងផ្តល់សក្ខីកម្មក្នុងខែតុលា ធ្លាប់បានធ្វើសម្ភាសន៍ស្រដៀងៗគ្នាដែរជាមួយនឹងជនជាប់ចោទខ្លះ។ ពុំមានចន្លោះប្រហោង ដែលត្រូវបំពេញ ពាក់ព័ន្ធនឹងបញ្ហាណាមួយក្នុងសំណុំរឿង០០២/០១ ដែលតម្រូវឲ្យសក្ខីកម្មរបស់សាក្សីអ្នកជំនាញ TCE-33 ទេ ឬវានឹងត្រូវការរយៈពេលពីរសប្តាហ៍បន្ថែមទៀតនៃពេលវេលាជំនុំជម្រះ ប្រសិនបើត្រូវស្តាប់សក្ខីកម្មរបស់សាក្សីអ្នកជំនាញ TCE-33 នោះ។

7. សម្រាប់គ្រប់ចេតនា និងគោលបំណងទាំងអស់ សាក្សីអ្នកជំនាញ TCE-33 បានកាត់ក្តីជាមុនរួចជាស្រេចចំពោះរឿងក្តីនេះ និងពុំអាចមានសមត្ថភាពធ្វើជាអ្នកជំនាញអព្យាក្រឹត និងយុត្តិធម៌បានឡើយ។ យោបល់ណាមួយដែលផ្ទុយពីនេះ គឺពុំសមហេតុផលឡើយ។ ក្នុងឆ្នាំ២០០៤ ខណៈពេលដែល អ.វ.ត.ក កំពុងត្រូវបានបង្កើតឡើង ហើយគ្រោងនឹងធ្វើការស៊ើបអង្កេត ការិយាល័យសហ

[17] *សូមមើល* ឧ. សក្ខីកម្មរបស់កាំង ហ្កេកអ៊ាវ ហៅ ឌុច, សាឡុត បាន និង អុង ថុងហឿង។

[18] សម្រាប់សៀវភៅរបស់លោកសាស្ត្រាចារ្យ Kiernan ពាក់ព័ន្ធនឹងមនោគមវិជ្ជាកុម្មុយនីស្ត *សូមមើល* BENEDICT KIERNAN, តើ ប៉ុល ពត ចូលកាន់អំណាចបែបណា? (ឆ្នាំ១៩៨៥), IS4.24, ពិសេស ជំពូក៨។ *សូមមើលផងដែរជាទូទៅ* BENEDICT KIERNAN របប ប៉ុល ពត (ឆ្នាំ១៩៩៦), IS4.25។

ព្រះរាជអាជ្ញាបានរៀបចំដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ) សាក្សីអ្នកជំនាញ TCE-33 ជាមួយនឹងអ្នកនិពន្ធម្នាក់ទៀត បានបោះពុម្ពផ្សាយសៀវភៅដែលមានចំណងជើងថា SEVEN CANDIDATES FOR PROSECUTION: ACCOUNTABILITY FOR THE CRIMES OF THE KHMER ROUGE (បេក្ខជនប្រាំពីរនាក់សម្រាប់ចោទប្រកាន់៖ ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម")។ សៀវភៅនេះបញ្ចូលឈ្មោះលោក អៀង សារី ជាបេក្ខជនម្នាក់ក្នុងចំណោម "បេក្ខជនទាំងប្រាំពីរនាក់" ដែរ[19]។

8. បន្ទាប់ពីបោះពុម្ពផ្សាយសៀវភៅនេះ សាក្សីអ្នកជំនាញ TCE-33 ត្រូវបានផ្តល់ឱកាសឲ្យផ្តល់សុពលភាព និងគាំទ្រការអះអាង ដែលគាត់សរសេរក្នុងសៀវភៅគាត់ នៅពេលគាត់បម្រើការឲ្យការិយាល័យសហព្រះរាជអាជ្ញា ដើម្បីស៊ើបអង្កេត និងរៀបចំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរប្រឆាំងនឹងលោក អៀង សារី និងជនជាប់ចោទផ្សេងៗទៀត។ បន្ទាប់មកទៀត សាក្សីអ្នកជំនាញ TCE-33 បម្រើការឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលគួរតែជាអង្គភាពស៊ើបអង្កេតអព្យាក្រឹត បង្កើតឡើងដើម្បីវាយតម្លៃភស្តុតាងគាំទ្រ និងប្រឆាំងនឹងជនជាប់ចោទ។ តាមការសន្មតសាក្សីអ្នកជំនាញ TCE-33 គួរបានកំណត់ឲ្យអនុវត្តការងារដោយអព្យាក្រឹតភាព ក្នុងការវាយតម្លៃការចោទប្រកាន់ដូចគ្នាដដែល ប្រឆាំងនឹងលោក អៀង សារី និងជនជាប់ចោទផ្សេងៗទៀតដែលខ្លួនគាត់ផ្ទាល់បានរៀបចំ បើទោះជាអាចមិនមែនជាការរំពឹងទុកពិត ប្រាកដរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ដូចដែលឆ្លុះបញ្ចាំងក្នុងគោលជំហររបស់ខ្លួន ដែលថាមានតែសហចៅក្រមស៊ើបអង្កេតប៉ុណ្ណោះដែលចាំបាច់ត្រូវមានឯករាជ្យភាព និងអនាគតិ[20]។

---

[19] STEPHEN HEDER & BRIAN TITTEMORE, SEVEN CANDIDATES FOR PROSECUTION: ACCOUNTABILITY FOR THE CRIMES OF THE KHMER ROUGE (ឆ្នាំ២០០៤)។

[20] ដូចគ្នាដែរ យុត្តិសាស្ត្រ ក៏បានរំលឹកផងដែរថា វិធានដែលចែងអំពីវិសមតិភាពនៃមុខងារ ដែលមានគោលដៅធានាឯករាជ្យភាព និងអនាគតិតុលាការនោះ សំដៅតែទៅលើចៅក្រមប៉ុណ្ណោះ និងមិនអនុវត្តចំពោះអ្នកអង្កេតទេ។ ដូច្នេះ ស្ថានភាពដែលលោកបានលើកឡើងនៅក្នុងលិខិតចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ គឺមិនបង្កជាបញ្ហាណាមួយដល់ឯករាជ្យភាព និងអនាគតិរបស់សហចៅក្រមស៊ើបអង្កេតទេ ហើយក៏មិនមានអ្វីប៉ះពាល់ដល់ដំណើរការល្អនៃការស៊ើបអង្កេត ដែលកំពុងតែដំណើរការនេះដែរ"។ លិខិតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនក្រុមមេធាវីការពារក្តី អៀង សារី "សំណើសុំផ្តល់ព័ត៌មានទាក់ទិននឹងករណីទំនាស់ផលប្រយោជន៍ជាយថាហេតុ" ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ២០០៨ ឯកសារ A121/I ទំព័រ២។

9. យោងតាមដំណើររឿងសាក្សីនៃអតីតប្រធានផ្នែកវិភាគ និងស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត គឺលោក Wayne Bastin ដែលជំនាញវិជ្ជាជីវៈខ្ពស់ដោយគ្មានការជំទាស់លើចំណុចនេះ[21] ក្នុងអំឡុងពេលបម្រើការឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត សាក្សីអ្នកជំនាញ TCE-33 បានចូលរួមការប្រជុំមួយក្នុងខែ សីហា ឆ្នាំ២០០៩ រវាងចៅក្រម Lemonde និងបុគ្គលិកអន្តរជាតិជាច្រើននៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៅគេហដ្ឋានរបស់លោកចៅក្រម Lemonde ក្នុងរាជធានីភ្នំពេញ។ ក្នុងការប្រជុំនេះ ចៅក្រម Lemonde បានណែនាំឲ្យសាក្សីអ្នកជំនាញ TCE-33 និងអ្នកផ្សេងៗទៀត ដែលមានវត្តមាន ស្វែងរកជាចម្បងនូវភស្តុតាងដាក់បន្ទុក ដែលផ្ទុយទៅនឹងការដឹកនាំការស៊ើបអង្កេតដែលមានលក្ខណៈមិនលំអៀងនោះ។ ចៅក្រម Lemonde បានថ្លែងថា គាត់ចង់ឲ្យក្រុម "**ស្វែងរកភស្តុតាងដាក់បន្ទុកជាងភស្តុតាងដោះបន្ទុក**"[22] សាក្សីអ្នកជំនាញ TCE-33 យោងទៅតាមការចងចាំរបស់លោក Bastin នៅស្ងាត់ស្ងៀម និងពុំជំទាស់អ្វីទេ[23]។

10. បន្ទាប់ពីលាឈប់ពីការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយសារតែការខកចិត្តរបស់គាត់ថា វាហាក់ដូចជាថា សំណុំរឿង០០៣ និង០០៤ នឹងមិនបន្តទៅមុខទេ[24] សាក្សីអ្នកជំនាញ TCE-33 បានបន្ត

---

[21] បច្ចុប្បន្ន លោក Bastin កំពុងបម្រើជាមន្ត្រីនគរបាលនៅប្រទេសអូស្ត្រាលី។ លោកមានបទពិសោធន៍ការងារ៣១ឆ្នាំ ភាគច្រើនក្នុងផ្នែកមនុស្សឃាត និងបទឧក្រិដ្ឋដែលមានអង្គការចាត់តាំង ដែលតួនាទីចម្បងរបស់គឺប្រធានផ្នែកស៊ើបការណ៍។ គាត់ធ្លាប់បម្រើការរយៈពេល១២ខែនៅតុលាការICTR ជាអ្នកស៊ើបអង្កេត/អ្នកវិភាគ និង១២ខែនៅតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ា-ឡេអូន ជាប្រធានផ្នែកស៊ើបការណ៍។ គាត់ក៏ធ្លាប់ធ្វើជាអ្នកស៊ើបអង្កេតជាន់ខ្ពស់នៅគណៈកម្មការពិសេសរបស់អង្គការសហ-ប្រជាជាតិសម្រាប់ប្រទេសទីម័រខាងកើត ក្នុងឆ្នាំ២០០៦ និងទទួលខុសត្រូវបង្កើតផ្នែកស៊ើបអង្កេត នៅអ.វ.ត.ក ក្នុងឆ្នាំ២០០៧។ គាត់បានវិលត្រឡប់មកធ្វើការឲ្យអ.វ.ត.កវិញ ក្នុងឆ្នាំ២០០៨ ក្នុងនាមជាប្រធានផ្នែកវិភាគ និងស៊ើបអង្កេត។

[22] បណ្ដឹងរបស់លោក អៀង សារី ដិតចិត្តនឹងសហចៅក្រមស៊ើបអង្កេត Marcel Lemonde & សំណើសុំឲ្យរៀបចំសវនាការសាធារណៈ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩,១, ឧបសម្ព័ន្ធ "ក" ទំព័រ១។

[23] *ដូចជើងទំព័រខាងលើ ទំព័រ២។*

[24] *សូមមើល ការការពារឯករាជ្យភាពតុលាការក្នុងតុលាការចម្រុះ៖ មេរៀនពីអ.វ.ត.ក និងការអនុវត្តល្អៗសម្រាប់ថ្ងៃអនាគត* របាយការណ៍របស់គណៈមេធាវីអន្តរជាតិ ចុះខែកញ្ញា ឆ្នាំ២០១១ សម្រង់លិខិតលាលែងរបស់សាក្សី TCE-33 ផ្ញើជូនទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត៖ "តាមសេចក្ដីសម្រេចរបស់ចៅក្រមក្នុងការបិទកិច្ចស៊ើបអង្កេតក្នុងសំណុំរឿង០០៣ដោយពុំបើកការស៊ើបអង្កេតក្នុងសំណុំរឿងនេះ ដែលខ្ញុំ ដូចអ្នកដទៃទៀតដែរ ជឿជាក់ថា ពុំសមហេតុផល។ តាមកំណើនកង្វះទំនុកចិត្តជាក់ស្ដែងរបស់បុគ្គលិកផ្នែកអង្គការសហប្រជាជាតិក្នុងការដឹកនាំរបស់លោកចៅក្រមដែលក្នុងនោះមានរូបខ្ញុំដែរហើយតាមបរិយាកាសពុលនៃកង្វះទំនុកចិត្តទាំងសងខាង កើតចេញពីការដឹកនាំរបស់លោកចៅក្រម ដែលបច្ចុប្បន្នក្លាយជាការិយាល័យ មិន

សរសេរអត្ថបទផ្សេងៗ ប៉ុន្មានប៉ងជះឥទ្ធិពលលើតុលាការនេះ ជាមួយនឹងអត្ថបទថ្មីៗចំនួនពីរ ដែលត្រូវបានបោះពុម្ពផ្សាយក្នុងខែ មេសា ឆ្នាំនេះ[25]។ ដូចឃើញច្បាស់ក្នុងចំណងជើង អត្ថបទមួយក្នុងចំណោមអត្ថបទទាំងនេះមានចំណងជើងថា *Communist Party of Kampuchea Policies on Class and on Dealing with Enemies Among the People and Within the Rovolutionary Ranks, 1960-1979* (*គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីវណ្ណៈ និងការ ដោះស្រាយជាមួយនឹងខ្មាំងសត្រូវក្នុងចំណោមប្រជាជន និងក្នុងជួរបដិវត្តន៍ ឆ្នាំ១៩៦០-១៩៧៩៖ មន្ទីរ, ស្រុក និងមូលដ្ឋាន*) ជាក់ស្តែងបានប៉ះពាល់ដល់បញ្ហានានាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ និងហាក់ដូចត្រូវបានបោះពុម្ពផ្សាយ ជាមួយនឹងចេតនាជះឥទ្ធិពលលើការធ្វើសេចក្តីសម្រេចតាមផ្លូវតុលាការក្នុងសំណុំរឿង០០២។

11. ក្នុងអត្ថបទមួយទៀត ក្រោមចំណងជើងថា *The Personal Jurisdiction of the Extraordinary Chambers in the Courts of Cambodia as regards Khmer Rouge "Senior Leaders" and Others "Most Responsible" for Khmer Rouge Crimes: History and Recent Developments* (*យុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់" ខ្មែរក្រហម និងអ្នកផ្សេងៗទៀត "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់ឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម៖ ប្រវត្តិសាស្ត្រ និងការវិវឌ្ឍថ្មីៗ*) សាក្សីអ្នកជំនាញ TCE-33 បានសរសេរសេចក្តីសង្ខេបដ៏វែងអន្លាយអំពីកិច្ចចរចាក្នុងការបង្កើត អ.វ.ត.ក មុននឹងឈានដល់សេចក្តីសន្និដ្ឋានមួយថា "ការបកស្រាយដ៏សមហេតុផលបំផុត បើនិយាយតាមផ្លូវច្បាប់" អំពីយុត្តាធិការបុគ្គល

---

ដំណើរការប្រក្រតីផ្នែកវិជ្ជាជីវៈ ហើយខ្ញុំបានសម្រេចថា ពុំមានសារៈប្រយោជន៍អ្វីពីសេវាផ្តល់ប្រឹក្សារបស់ខ្ញុំឡើយ"។

[25] Stephen Heder *យុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់" ខ្មែរក្រហម និងអ្នកផ្សេងៗទៀត "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់ឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម៖ ប្រវត្តិសាស្ត្រ និងការវិវឌ្ឍថ្មីៗ* ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២។ Stephen Heder *គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីវណ្ណៈ និងការដោះស្រាយជាមួយនឹងខ្មាំងសត្រូវក្នុងចំណោមប្រជាជន និងក្នុងជួរបដិវត្តន៍ ឆ្នាំ១៩៦០-១៩៧៩៖ មន្ទីរ, ស្រុក និងមូលដ្ឋាន* ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២។

របស់អ.វ.ត.ក គឺថាវាគួររាប់បញ្ចូលទាំងមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាកម្រិតកណ្តាលផងដែរ[26]។ ពេល វេលានៃការបោះពុម្ពផ្សាយអត្ថបទនេះ គឺស្របគ្នានឹងការពិចារណារបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតអំពីថាតើ អ.វ.ត.ក មាន ឬគ្មានយុត្តាធិការក្នុងការស៊ើបអង្កេតជនសង្ស័យក្នុងសំណុំរឿង០០៣ និង០០៤ ដែលនាំឲ្យមានសេចក្តីសន្និដ្ឋានថា សាក្សីអ្នកជំនាញ TCE-33 បោះពុម្ពផ្សាយអត្ថបទនេះ ជាមួយនឹងចេតនាចង់មានឥទ្ធិពលលើការធ្វើសេចក្តីសម្រេចតាមផ្លូវតុលាការ។ ចំណុចនេះហាក់ដូចជាទំនងខ្លាំងណាស់ ដោយសារថា សាក្សីអ្នកជំនាញ TCE-33 បច្ចុប្បន្នកំពុងបម្រើការឲ្យអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) ដែលនាយកប្រចាំទ្វីបអាស៊ីនៃអង្គការនេះត្រូវបានស្រង់សំដីក្នុងខែ វិច្ឆិកា ឆ្នាំ២០១១ ថា "ប្រសិនបើសំណុំរឿងបន្ថែមទៀតមិនត្រូវបានអនុញ្ញាតឲ្យបន្តទៅមុខទេនោះ នឹងមានមនុស្សតែបួននាក់ប៉ុណ្ណោះទទួលការជំនុំជម្រះសម្រាប់គ្រាដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្រនេះ។ ការកំណត់បែបនេះនឹងអនុញ្ញាតឲ្យមន្ត្រីខ្មែរក្រហមជាច្រើននាក់ដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅទ្រង់ទ្រាយធំ បន្តរស់នៅដោយសេរី ដោយអ្នកខ្លះកំពុងរស់នៅក្នុងសហគមន៍តែមួយ ដែលពួកគេបានអនុវត្តការសម្លាប់ទ្រង់ទ្រាយធំ"[27]។ ការផ្តល់សក្ខីកម្មរបស់សាក្សីអ្នកជំនាញ TCE-33 នឹងមានលក្ខណៈជាការព្យាយាមសម្រេចលទ្ធផលគ្រោងទុកជាមុន ដោយសក្ខីកម្មនោះមានចេតនាលើកកម្ពស់វិជ្ជាជីវៈសិក្សាផ្ទាល់ខ្លួនរបស់គាត់ និងជម្រុញគោលជំហររបស់គាត់ដែលថា សំណុំរឿង០០៣ និង០០៤ គួរត្រូវបានអនុវត្តបន្ត។

12. ចុងក្រោយ សហមេធាវីការពារក្តីមានភស្តុតាងបន្ថែមបង្ហាញអំពីភាពពុំសក្តិសមរបស់សាក្សីអ្នកជំនាញ TCE-33 ក្នុងការផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ ដោយភស្តុតាងនោះបង្ហាញថា សាក្សីអ្នកជំនាញ TCE-33 ប្រហែលជា ត្រូវបានជួលឲ្យបម្រើការឲ្យទីភ្នាក់ងារស៊ើបការណ៍មជ្ឈិម("សេ.អ៊ី.អា") របស់សហរដ្ឋអាមេរិក ក្នុងអំឡុងពេលពាក់ព័ន្ធនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលនេះជាការចោទប្រកាន់ដែលសាក្សីអ្នកជំនាញ TCE-33 ខកខានមិនបានច្រានចោល បន្ទាប់ពីការចោទប្រកាន់នេះ

---

[26] Stephen Heder *យុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក់ព័ន្ធនឹង "មេដឹកនាំជាន់ខ្ពស់" ខ្មែរក្រហម និងអ្នកផ្សេងៗទៀត "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់ឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម៖ ប្រវត្តិសាស្ត្រ និងការវិវឌ្ឍថ្មីៗ* ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២ ទំព័រ៤២។

[27] Brad Adams *ការជំនុំជម្រះពួកខ្មែរក្រហមកំពុងធ្វើឲ្យជនរងគ្រោះពីរបប ប៉ុល ពត ខកចិត្ត* សារព័ត៌មាន GUARDIAN ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ *អាចមើលបាននៅ*http://www.hrw.org/news/2011/11/23/khmer-rouge-trial-failing-cambodian-victims-pol-pots-regime.

ត្រូវបានដាក់ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងខែមករា ឆ្នាំ ២០០៩[28]។ ការងារបែបនេះនឹងពិតជាប៉ះពាល់ដល់សមត្ថភាពរបស់សាក្សីអ្នកជំនាញ TCE-33 ក្នុងការវាយតម្លៃភស្តុតាង និងផ្តល់មតិយោបល់ដោយអព្យាក្រឹត។ ប្រសិនបើ វាជារឿងពិតប្រាកដមែន ដែលថា សាក្សីបានធ្វើការឱ្យ សេ.អ៊ី.អា សហមេធាវីការពារក្តីស្នើសុំឱ្យមានការជូនដំណឹងអំពីព័ត៌មានពិស្តារនៃការងារនេះ មុនពេលមានការផ្តល់សក្ខីកម្មរបស់សាក្សីអ្នកជំនាញ TCE-33 ដើម្បីឱ្យយើងខ្ញុំអាចត្រៀមរៀបចំបានសមស្របសម្រាប់ការដេញដោលសួររូបគាត់។

13. មេធាវីការងារក្តីកត់សម្គាល់ឃើញថា នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានច្រានចោលសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ក្នុងការតែងតាំងសាក្សីអ្នកជំនាញ TCE-33 ជាអ្នកជំនាញ។ ក្នុងចំណោមហេតុផលផ្សេងៗមួយចំនួន ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា "សហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ក្រៅអំពីបញ្ហាដែលពាក់ព័ន្ធនឹងការវាយតម្លៃពីលក្ខណៈវិនិច្ឆ័យដែលតម្រូវឱ្យមានរបស់អ្នកទាំងនោះ *អាស្រ័យដោយអ្នកខ្លះក្នុងចំណោមពួកគេ [អ្នកជំនាញដែលបានស្នើសុំ] ដែលបច្ចុប្បន្ន ឬពីមុនជា បុគ្គលិកនៃភាគីមួយនៃរឿងក្តីនីតិវិធី...ឬជាបុគ្គលិករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ ([សាក្សីអ្នកជំនាញ TCE-33])' នោះ វានឹង មិនមែនជាផលប្រយោជន៍ប្រសើរខាងយុត្តិធម៌ទេ ប្រសិនបើចាត់តាំងពួកគេជាអ្នកជំនាញ* ដែលកំណត់ដោយវិធាន ៣១ នៃវិធានផ្ទៃក្នុងនៅក្នុងដំណាក់កាលនេះ"[29]។ អង្គជំនុំជម្រះសាលាដំបូងគួរអនុវត្តតាមវិធីសាស្ត្រនេះ និងគួរប្រកាសថា វានឹងមិនមែនជាផលប្រយោជន៍ប្រសើរខាងយុត្តិធម៌ទេ ក្នុងការកោះ ហៅសាក្សីអ្នកជំនាញ TCE-33មកធ្វើជាអ្នកជំនាញនោះ។

14. វិធីសាស្ត្រនេះ គឺស្របគ្នានឹងយុត្តិសាស្ត្ររបស់តុលាការ ICTY។ តុលាការ ICTY អនុវត្តប្រព័ន្ធកូនកាត់ ដែលនៅក្នុងប្រព័ន្ធនេះ ការទទួលយកភស្តុតាងមានលក្ខណៈដូចគ្នាខ្លាំងណាស់ទៅនឹងប្រព័ន្ធច្បាប់

---

[28] *សូមមើល* សំណើសុំព័ត៌មានពាក់ព័ន្ធនឹងអត្ថិភាពសក្តានុពលនៃជម្លោះផលប្រយោជន៍របស់អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឈ្មោះ Stephen Heder ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ឯកសារ A252។

[29] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D281/3 កថាខណ្ឌ៦ (គូសបញ្ជាក់បន្ថែម)។

ស៊ីវិល[30]។ ទោះជាយ៉ាងនេះក្តី កិច្ចដំណើរការជំនុំជម្រះមានលក្ខណៈតទល់មុខគ្នា និងអនុវត្តតាមសំណើរបស់ភាគី មានន័យថា ភាគីអាចជ្រើសរើសសាក្សីផ្ទាល់ខ្លួន (ជាជាងគ្រាន់តែដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង)។ បើទោះជាក្នុងប្រព័ន្ធដែលអនុវត្តតាមសំណើរបស់ភាគីក្តី អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY បានបដិសេធមិនព្រមស្តាប់អ្នកជំនាញ ដែលអង្គជំនុំជម្រះយល់ថាមានទំនាក់ទំនងជិតស្និទ្ធពេកនឹងភាគីណាមួយ។ ឧទាហរណ៍ ក្នុងការជំនុំជម្រះ *Milutinović និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូងមិនបានអនុញ្ញាតឲ្យបុគ្គលិករបស់ការិយាល័យរដ្ឋអាជ្ញាផ្តល់ភស្តុតាង ក្នុងនាមជាអ្នកជំនាញទេ[31]។ ដូចគ្នាដែរ ក្នុងរឿងក្តី *Đorđević* អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា៖

> ខណៈការព្រួយបារម្ភពាក់ព័ន្ធនឹងឯករាជ្យភាពរបស់សាក្សីអ្នកជំនាញតែងតែត្រូវបានពិចារណាថាជាបញ្ហានៃទម្ងន់ភស្តុតាង ជាជាងភាពអាចទទួលយកបាន ការចូលរួមក្នុងសំណុំរឿងជាក់លាក់មួយអាចថា ភាពជឿជាក់បាននៃមតិយោបល់របស់អ្នកជំនាញ ចាំបាច់ត្រូវតែដេញដោល។ [...] អង្គជំនុំជម្រះរកឃើញថា Philip Coo បើទោះជាបានបំពេញលក្ខណៈវិនិច្ឆ័យដែលតម្រូវក្នុងនាមជាសាក្សីអ្នកជំនាញក៏ដោយ ពុំគួរផ្តល់ភស្តុតាង ក្នុងនាមជាអ្នកជំនាញទេ ដោយសារតែ *វិសាលភាពនៃការចូលរួមរបស់គាត់ក្នុងការរៀបចំសំណុំរឿងក្នុង*

---

[30] វិធានទូទៅក្នុងតុលាការអន្តរជាតិ គឺត្រូវទទួលយកភស្តុតាងដោយសេរី និងពិចារណាលើទម្ងន់ភស្តុតាងនោះនៅចុងបញ្ចប់ការជំនុំជម្រះ ក្នុងបរិបទនៃប្រតិចារឹកជំនុំជម្រះទាំងស្រុង។ *សូមមើល* ចៅក្រម RICHARD MAY & MARIEKE WIERDA, INTERNATIONAL CRIMINAL EVIDENCE 93 (Transnational Publishers, Inc. ឆ្នាំ២០០២) "ពាក់ព័ន្ធនឹងបញ្ហានេះ "In this ការជំនុំជម្រះព្រហ្មទណ្ឌអន្តរជាតិ ដូចគ្នានឹងការជំនុំជម្រះព្រហ្មទណ្ឌ អនុវត្តក្នុងប្រព័ន្ធច្បាប់ស៊ីវិល ប្រតិបត្តិក្រោម "ការវាយតម្លៃភស្តុតាងដោយសេរី"។

[31] សូមមើល *រដ្ឋអាជ្ញា តទល់នឹង Milutinović* អ្នកផ្សេងៗទៀត ឯកសារ IT-05-87-T សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំការគូសបញ្ជាក់ពីបណ្តឹងចាត់របៀបនៃសេចក្តីសម្រេចលើការទទួលយករបាយការណ៍សាក្សីរបស់សាក្សី Philip Coo ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ កថាខណ្ឌ១។ សេចក្តីសម្រេចនេះពន្យល់ថា នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចផ្ទាល់មាត់ពាក់ព័ន្ធនឹងសាក្សីអ្នកជំនាញ Philip Coo ដែលអង្គជំនុំជម្រះ "បានសម្រេចយករូបគាត់ធ្វើជាសាក្សី"និងបានសម្រេចថា របាយការណ៍របស់គាត់នឹង"មិនត្រូវបានទទួលយកជារបាយការណ៍អ្នកជំនាញ"ឡើយ។ អង្គជំនុំជម្រះក៏បានសម្រេចដែរថា"ដោយសារគាត់មានទំនាក់ទំនងជិតស្និទ្ធពេកនឹងក្រុមរដ្ឋអាជ្ញា គាត់ពុំអាចត្រូវបានចាត់ទុកជាអ្នកជំនាញបានឡើយ"។

*ការិយាល័យរដ្ឋអាជ្ញា ដូច្នេះ អង្គជំនុំជម្រះពុំមានទំនុកចិត្តលើអព្យាក្រឹតភាពនៃមតិយោបល់របស់គាត់ឡើយ*[32]។

នៅ អ.វ.ត.ក បទដ្ឋានគួរតែមានកម្រិតខ្ពស់ជាងបទដ្ឋានដែលអនុវត្តដោយតុលាការ ICTY ទៀត ដោយហេតុថា អ្នកជំនាញនៅ អ.វ.ត.ក ត្រូវតែងតាំងដោយអង្គជំនុំជម្រះសាលាដំបូង មិនមែនដោយភាគីទេ។ គ្រោះថ្នាក់មួយដែលត្រូវបានទទួលស្គាល់ក្នុងការសិក្សាជាច្រើន[33] គឺថា អ្នកជំនាញអាចមានទំនាក់ទំនងសង្គមជាមួយនឹងភាគី ដែលខ្លួនបម្រើការឲ្យ (ឬ ក្នុងករណីនេះ ខ្លួនធ្លាប់ធ្វើជាបុគ្គលិក) ព្រោះថា៖

---

[32] *រដ្ឋអាជ្ញាតទល់នឹង Đorđević* ឯកសារ IT-05-87/1-T សេចក្ដីសម្រេចលើការកត់សម្គាល់របស់ក្រុមមេធាវីការពារក្ដី ក្រោមវិធាន៩៤ *ស្ទួន* ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ១៩-២០ (គូសបញ្ជាក់បន្ថែម)។

[33] "ទោះជាយ៉ាងណាក៏ដោយ អស់ជាច្រើនឆ្នាំមកហើយ ប្រធានបទនៃភាពលំអៀង ត្រូវបានសិក្សាក្នុងស្ថានភាពពិសោធន៍ដែលមានការគ្រប់គ្រងល្អ ដោយអ្នកសិក្សាស្រាវជ្រាវក្នុងវិស័យចិត្តវិទ្យាសាស្ត្រ និងសេដ្ឋកិច្ចអាកប្បកិរិយា។ ការសិក្សាទាំងនេះបង្ហាញថា ពុំមានការអនុវត្តដាច់ខាត ដែលមិនលំអៀងទេ។ ក្នុងការសិក្សាបែបនេះ កត្តាចម្បងពីរត្រូវបានបង្ហាញថាជម្រើសលំអៀង។ មួយគឺភាពញឹកញាប់ ដែលជម្រើសមួយត្រូវបានអនុវត្តជាងជម្រើសមួយទៀត៖ អតុល្យភាពមួយអាចកើតឡើង នៅពេលមនុស្សម្នាក់ផ្ដល់សក្ខីកម្មជាប្រចាំឲ្យតែម្ខាង" Michael Lamport Commons, PhD, Patrice Marie Miller, EdD, & Thomas G. Gutheil, MD, *ចំណាប់អារម្មណ៍របស់សាក្សីអ្នកជំនាញអំពីភាពលំអៀងក្នុងចិត្តអ្នកជំនាញ*, 32 J. AM ACAD PSYCHIATRY L. 70, 70 (ឆ្នាំ២០០៤)។ "ទោះជាយ៉ាងនេះក្ដី អ្វីដែលគួរឲ្យរំខានជាងគេនោះ គឺការសិក្សានេះបង្ហាញថា តួនាទីតទល់មុខគ្នាប៉ះពាល់ដល់លក្ខណៈនៃសក្ខីកម្ម ដែលផ្ដល់ដោយសាក្សីម្នាក់។ ឧទាហរណ៍ សាក្សីដែលត្រូវបានស្ដាប់ចម្លើយមុននឹងការផ្ដល់សក្ខីកម្មដោយមេធាវីតទល់មុខគ្នា បានបង្ហាញឲ្យឃើញថា នឹងផ្ដល់សក្ខីកម្មដែលមានភាពលំអៀងជាងសាក្សីដែលត្រូវបានស្ដាប់ចម្លើយមុនដោយមេធាវីមិនតទល់មុខគ្នា ហើយការសិក្សាមួយបង្ហាញថា មតិយោបល់នៃអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តមានលក្ខណៈខុសគ្នា អាស្រ័យទៅលើភាគីដែលប្រើប្រាស់ពួកគេ"។ Nancy J. Brekke, Peter J. Enko, Gail Clavet, & Eric Seelau, *Of គណៈវិនិច្ឆ័យ និងអ្នកជំនាញចាត់តាំងដោយតុលាការ៖ ផលប៉ះពាល់នៃសក្ខីកម្មអ្នកជំនាញតទល់មុខគ្នា ខុសគ្នាពី សក្ខីកម្មអ្នកជំនាញមិនតទល់មុខគ្នា* 15(5) LAW & HUM. BEHAV. 451, 453 (ឆ្នាំ១៩៩១) (សម្រង់ផ្នែកក្នុងត្រូវបានលុបចេញ)។ *សូមមើលផងដែរ* Lawrence A. Ponemon, *សត្យានុម័តនៃសាលក្រមគាំទ្របណ្ដឹងវិវាទរបស់គណនេយ្យ* 70(3) ACCOUNTING REV. 467 (ឆ្នាំ១៩៩៥)។

ដំណើរការដែលអ្នកជំនាញត្រូវបានជ្រើសរើស រក្សាទុក និងរៀបចំសម្រាប់ការជំនុំជម្រះ ធ្វើឲ្យគាត់មានអារម្មណ៍ដូចជាថា ពួកគេជាសមាជិកនៃក្រុមដែលតទល់មុខគ្នា។ ច្បាប់លើកឡើងថាជាសាក្សី ប៉ុន្តែដំណើរការដែលអ្នកជំនាញក្លាយជាសាក្សីបញ្ចូនសារផ្ទុយពីនេះ[34]។

ករណីនេះដូចគ្នាចំពោះសាក្សីអ្នកជំនាញ TCE-33 ដែរ។ អង្គជំនុំជម្រះសាលាដំបូងត្រូវតែច្រានចោលសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ក្នុងការស្តាប់រូបគាត់ក្នុងនាមជាអ្នកជំនាញ។ សក្ខីកម្មរបស់គាត់នឹងមិនជួយដល់អង្គជំនុំជម្រះសាលាដំបូងឡើយ ប៉ុន្តែនឹងគ្រាន់តែធ្វើឲ្យប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ។ សាក្សីអ្នកជំនាញ TCE-33 ពុំមែនជាអ្នកជំនាញឥតលំអៀង ឬឯករាជ្យម្នាក់ឡើយ ប៉ុន្តែជាអ្នកតស៊ូមតិដ៏លំអៀងម្នាក់។

**ឃ. សាក្សី TCW-720**

15. មេធាវីការពារក្តីពុំយល់ឃើញថា សាក្សីនេះនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការបញ្ជាក់អំពីការពិតឡើយ ត្បិតគាត់ពុំមានចំណេះដឹងពាក់ព័ន្ធផ្ទាល់អំពីការចោទប្រកាន់ ដែលមានចែងក្នុងដីកាដំណោះស្រាយឡើយ។ ប្រសិនបើសាក្សីរូបនេះត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម សហមេធាវីការពារក្តីស្នើសុំទៅអង្គជំនុំជម្រះកំណត់ឲ្យគាត់ផ្តល់មុនពេលគាត់ធ្វើសក្ខីកម្ម នូវសំឡេង និងរូបភាពនៃការធ្វើសម្ភាសន៍របស់គាត់ទាំងស្រុងជាមួយលោក នួន ជា និងជាមួយបុគ្គលផ្សេងៗទៀត ពាក់ព័ន្ធ នឹងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងការសម្ភាសន៍នេះ អាចមានព័ត៌មានដោះបន្ទុក ដែលពុំត្រូវបានសរសេរក្នុងសៀវភៅ ឬខ្សែភាពយន្តគាត់ ដែលសហមេធាវីការពារក្តីចង់ដេញដោលសួរសាក្សីនេះ។

**ង. សាក្សី TCW-781 និងសាក្សី TCW-164**

16. មេធាវីការពារក្តីកត់សម្គាល់ឃើញថា យោងទៅតាមសេចក្តីសង្ខេបអំពីសាក្សីរបស់ការិយាល័យសហព្រះរាជអាជ្ញា និងការលើកឡើងរបស់ការិយាល័យសហព្រះរាជអាជ្ញាក្នុងកិច្ចប្រជុំរៀបចំសវនាការ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០១២ សាក្សីទាំងនេះពាក់ព័ន្ធជាចម្បងនឹងលោក នួន ជា និងលោក ខៀវ សំផន។ យោងទៅតាមសេចក្តីសង្ខេបអំពីសាក្សីរបស់ការិយាល័យសហព្រះរាជអាជ្ញា សាក្សីទាំងនេះអាចនិយាយផងដែរអំពី "របកគំហើញអង្គហេតុនៃសហឧក្រិដ្ឋកម្ម

[34] Michael J. Saks, *សាក្សីអ្នកជំនាញ, សាក្សីមិនមែនអ្នកជំនាញ និងអ្នកជំនាញមិនមែនសាក្សី*, 14(4) LAW & HUM. BEHAV. 291, 309 (ឆ្នាំ១៩៩០)។

រួម ពោលគឺមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស"[35]។ ដោយការិយាល័យសហព្រះរាជអាជ្ញាបានអះអាងថា សក្ខីកម្មនៃសាក្សីទាំងនេះនឹងមានរយៈពេល"ខ្លី"មែនទែននោះ[36] សហមេធាវីការពារក្តីសូមឲ្យអង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើត្រូវ ឬមិនត្រូវកោះហៅសាក្សីទាំងនេះ ប៉ុន្តែសហមេធាវីការពារក្តីសូមកត់សម្គាល់ថា ពួកគេមិនត្រូវអនុញ្ញាតឲ្យនិយាយអំពីមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សឡើយ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចមិនពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ដើម្បីរាប់បញ្ចូលទីតាំងទាំងនេះទាំងនោះទេ។

**អាស្រ័យហេតុនេះ** ដោយមានមូលហេតុដូចបានបញ្ជាក់ក្នុងសំណើនេះ មេធាវីការពារក្តីសូមស្នើដោយគោរពឲ្យអង្គជំនុំជម្រះសាលាដំបូងច្រានចោលសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា សុំកោះហៅសាក្សី TCW-505, TCW-754, TCW-100, TCE-33, TCW-720, TCW-781 និងសាក្សី TCW-164។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី**១៤** ខែ**កញ្ញា** ឆ្នាំ**២០១២**

| | |
|---|---|
| **អាង ឧត្តម** | Michael G. KARNAVAS |

សហមេធាវីរបស់លោក **អៀង សារី**

[35] សេចក្តីសង្ខេបអំពីអ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ជាមួយនឹងចំណុច ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ – ការិយាល័យសហព្រះរាជអាជ្ញា ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E9/13.1 ទំព័រ៥១-៥២ និង៦៣។

[36] ប្រតិចារឹក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/114.1 ទំព័រ២៣។